00665574

E0/29

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

| ឯកសារដើម |
|---|
| DOCUMENT RECEIVED/DOCUMENT REÇU |
| ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 19 / 04 / 2011 |
| ម៉ោង (Time/Heure): 15:30 |
| មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun |

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: លោក ខៀវ សំផន

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: បារាំង

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ (ឧបសម្ពន្ធសំងាត់)

ចំណាត់ថ្នាក់ឯកសារដោយ អ.ជ.ស.ដ សាធារណៈ / Public

ស្ថានភាពនៃចំណាត់ថ្នាក់:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

# បញ្ជីឯកសារ

| **ដាក់ដោយ៖** | **ផ្ញើជូន៖** | **ផ្ញើជូន៖** |
|---|---|---|
| មេធាវីការពារក្តី លោក ខៀវ សំផន | អង្គជំនុំជម្រះសាលាដំបូង | សហព្រះរាជអាជ្ញា |
| លោក ស សូវាន | ចៅក្រម និល ណុន | លោកស្រី ជា លាង |
| លោក Jacques VERGÈS | ចៅក្រម Silvia CARTWRIGHT | លោក Andrew CAYLEY |
| លោក Philippe GRECIANO | ចៅក្រម យូ អុត្តរា | |
| | ចៅក្រម Jean-Marc | |

| | | |
|---|---|---|
| **សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**<br>លោក ពេជ អង្គ<br>លោកស្រី Elisabeth SIMONNEAU FORT | LAVERGNE<br>ចៅក្រម យ៉ា សុខន | |

# សូមគោរពអង្គជំនុំជម្រះសាលាដំបូង

## I. សេចក្តីផ្តើម

១. យោងទៅលើដីការបស់អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ដោយអនុវត្តនូវវិធាន ៨០ នៃវិធានផ្ទៃក្នុង[1] នៅថ្ងៃនេះ លោក ខៀវ សំផន សូមផ្តល់ជូន **ក្នុងពេលទន្ទឹងមគ្នានឹងភាគីដទៃទៀតដែរ** នូវបញ្ជីឯកសារ ដែលលោកមានបំណងបង្ហាញជូនដល់អង្គជំនុំជម្រះ។

២. ថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១ លោក ខៀវ សំផន បានដាក់សំណើទូទៅមួយសុំឲ្យមានការពន្យារពេលដាក់វត្ថុតាង[2]។

៣. នៅក្នុងថ្ងៃដដែល អង្គជំនុំជម្រះបានបញ្ជាក់នៅក្នុងអនុស្សរណៈមួយ ពីគោលបំណងរបស់ខ្លួនក្នុងការបដិសេធនូវរាល់សំណើសុំពន្យារពេលដាក់ឯកសារភ័ស្តុតាង ដើម្បីរៀបចំសវនាការ។[3]

៤. ថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១[4] អង្គជំនុំជំរះបានបដិសេធសំណើថ្មីមួយទៀតរបស់លោក ខៀវ សំផន ដើម្បីសុំពន្យារពេលពិសេស សម្រាប់ការដាក់បញ្ជីឯកសាររបស់លោក។[5]

---

[1] ដីកាបង្គាប់ឲ្យភាគីដាក់សម្ភារៈដើម្បីរៀបចំសវនាការ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០១១ ឯកសារលេខ E9

[2] សំណើសុំពន្យារពេលដាក់ឯកសារភ័ស្តុតាង ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E9/6

[3] អនុស្សរណៈរបស់អង្គជំនុំជម្រះដែលមានចំណងជើងថា "ការជូនដំណឹងជាមុនអំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះទាក់ទងនឹងឯកសារដែលមានលេខ E14, E15, E9/2, E9/3, E24 និង E27 ចុះថ្ងៃទី ៨ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E35

[4] សេចក្តីសម្រេចលើសំណើនានាដែលបានស្នើសុំពន្យារពេលដើម្បីដាក់បញ្ជីឯកសារ និងវត្ថុតាង ចុះថ្ងៃទី ២៩ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ E9/16/4

[5] ការដាក់បញ្ជីឯកសារ និងភ័ស្តុតាង ការស្នើសុំពន្យារថិរវេលា ចុះថ្ងៃទី ២៥ ខែ មីនា ឆ្នាំ ២០១១ ឯកសារលេខ E9/16/2

## II. កិច្ចពិភាក្សា

### ស្ដីពីការរំលោភសិទ្ធិជាសារវន្តរបស់ លោក ខៀវ សំផន

៥. នៅក្នុងសំណើសុំពន្យារពេលដាក់បញ្ជីឯកសារទាំងពីរលើករបស់លោក លោក ខៀវ សំផន បានបង្ហាញរួចមកហើយថា ការអនុវត្តវិធាន ៨០ នៃវិធានផ្ទៃក្នុង រំលោភលើសិទ្ធិជាសារវន្តបំផុតរបស់លោក រួមមានសិទ្ធិទទួលបាននូវសច្ចធារណ៍និរទោស (សិទ្ធិជាប្រពៃណីនេះមានប្រភពនៅក្នុងមាត្រា ៩ នៃសេចក្ដីប្រកាសជាសកលស្ដីអំពីសិទ្ធិមនុស្ស និងសិទ្ធិពលរដ្ឋ ឆ្នាំ ១៧៨៩) ដែលជាគោលការណ៍មួយចែងថា បន្ទុកនៃការស្វែងរកភ័ស្ដុតាងបញ្ជាក់ពីពិរុទ្ធភាពរបស់លោកធ្លាក់ទៅលើសហព្រះរាជអាជ្ញា និងសិទ្ធិទទួលបានពេលវេលា និងភាពងាយស្រួលចាំបាច់នានាសម្រាប់រៀបចំការការពារក្ដីរបស់ខ្លួន ប្រកបដោយសមភាពពេញលេញ ព្រមទាំងសិទ្ធិក្នុងការទទួលបានការកាត់ក្ដីមួយ ដែលមិនមានការយឺតយ៉ាវហួសហេតុពេក។

៦. ម៉្យាងវិញទៀត នៅក្នុងសេក្ដីសម្រេចរបស់ខ្លួន ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១១ អង្គជំនុំជម្រះបានបញ្ជាក់ទាក់ទងនឹងបញ្ជីសាក្សី និងអ្នកជំនាញថា ៖ "បញ្ជីឈ្មោះរបស់ការិយាល័យសហព្រះរាជអាជ្ញា ផ្ដល់**មូលដ្ឋាន**ដែលភាគីផ្សេងទៀតអាចស្នើសុំឱ្យកោះហៅបុគ្គលដទៃទៀតពាក់ព័ន្ធនឹងការលើកឡើង នៅក្នុងដីកាបញ្ជូនរឿងទៅជំនុំជម្រះ"[6]។

៧. មិនមានហេតុផលដែលអាចជឿជាក់ណាមួយបញ្ជាក់បានថា គោលការណ៍នេះក៏មិនអាចអនុវត្តបានដែរ ចំពោះការដាក់បញ្ជីឯកសារនោះទេ។ ជាក់ស្ដែង ទោះជាក្នុងករណីណាក៏ដោយ ការដាក់បញ្ជីទាំងនេះត្រូវធ្វើឡើងបន្ទាប់ពីភាគីការពារក្ដីបានយល់ជ្រួតជ្រាបពីភ័ស្ដុតាងដាក់បន្ទុក ដែលដាក់ដោយភាគីដទៃទៀត និងជាពិសេស ដោយសហព្រះរាជអាជ្ញា។

៨. ដូច្នេះ នៅថ្ងៃនេះ លោក ខៀវ សំផន ត្រូវបង្ខំចិត្តដាក់បញ្ជីឯកសាររបស់ខ្លួន ទាំងខុសច្បាប់ដោយរំលោភលើសិទ្ធិជាសារវន្ត និងសិទ្ធិមនុស្ស។

---

[6] សេចក្ដីសម្រេចលើសំណើសុំរបស់មេធាវីការពារក្ដីពាក់ព័ន្ធនឹងការដាក់សម្ភារៈ ដើម្បីរៀបចំសវនាការ និងការដាក់អញ្ញត្រកម្ម ចុះថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០១១ ឯកសារលេខ E35/2 កថាខណ្ឌ ១១

## ស្តីពីនត្ថិភាពជាក់ស្តែងនៃរាល់ធាតុផ្សំនៃសំណុំរឿង

៩. ដើម្បីបញ្ជាក់មូលហេតុនៃការបដិសេធសំណើសុំពន្យារពេល អង្គជំនុំជម្រះបានផ្អែកទៅលើអនុសារណៈសាមញ្ញមួយ និងគ្រាន់តែលើកឡើងអំពីការដែលភាគីអាចមើលសំណុំរឿងបាន ចាប់តាំងដើមដំបូងនៃដំណើរការនីតិវិធីប៉ុណ្ណោះ។

១០. ក៏ប៉ុន្តែ នេះគឺជាការមិនត្រឹមត្រូវ ពីព្រោះថា តាមពិត សំណុំរឿងត្រូវបានចងក្រងឡើងបន្តិចម្តងៗ ទៅតាមការស៊ើបអង្កេត ហើយ លោក ខៀវ សំផន មិនអាចពិនិត្យមើលសំណុំរឿងទាំងមូល ចាប់តាំងពីដើមដំបូងនៃដំណើរការនីតិវិធីនោះទេ នេះមិនទាន់ទាំងរាប់បញ្ចូលបញ្ហាធ្ងន់ធ្ងរនៃការបកប្រែផង។ ហេតុដូចនេះហើយ រហូតមកដល់ថ្ងៃនេះ លោកនៅតែទទួលបាននូវការជូនដំណឹងអំពីឯកសារមួយចំនួនជាភាសាអង់គ្លេស ហើយបន្ទាប់មកជាភាសាបារាំង។ ដូច្នេះ លោកនៅតែមិនមានពេលវេលា និងភាពងាយស្រួលចាំបាច់ក្នុងការរៀបចំការការពារក្តីរបស់ខ្លួន។ គឺដោយសារមូលហេតុនេះហើយបានជា ជាក់ស្តែង គាត់មិនអាចបញ្ជាក់ពីទំនាក់ទំនងរវាងឯកសារដែលត្រូវបានជ្រើសរើស និងដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដូចដែលមានបង្ហាញនៅក្នុងគំរូតារាងដែលផ្តល់ដោយអង្គជំនុំជម្រះបាននោះឡើយ។

១១. ចំនួនឯកសារដ៏ច្រើនសម្បើមនៅក្នុងសំណុំរឿង ០០២ ព្រមទាំងអវត្តមាន ឬកង្វះខាតដ៏ធ្ងន់ធ្ងរក្នុងការបកប្រែឯកសារមួយចំនួនជាភាសាបារាំង[7] ធ្វើឲ្យការពិនិត្យមើលឯកសារក្នុងសំណុំរឿងមានលក្ខណៈបែប**ទ្រឹស្តី និងមិនជាក់ស្តែង**។ ហេតុដូច្នេះហើយ បានជាលោកមិនមានលទ្ធភាពជាក់ស្តែងអាចយល់ជ្រួតជ្រាបនូវរាល់ឯកសារទាំងឡាយនៅក្នុងសំណុំរឿង ០០២ និងរៀបចំឯកសារពីមួយទៅមួយទៅតាមផែនការបានឡើយ។

១២. ទាក់ទងនឹងចំនុចនេះ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរវ៉ាន់ដា បានគូសបញ្ជាក់ពីសារៈសំខាន់ សម្រាប់ជនជាប់ចោទក្នុងការ "**ពិនិត្យមើលឯកសារបានយ៉ាងងាយស្រួល**" យ៉ាងពិតប្រាកដ នៅពេលដែលឯកសារទាំងនេះមាននៅក្នុងមូលដ្ឋានទិន្នន័យអេឡិចត្រូនិក។ អង្គជំនុំជម្រះរំលឹកដូច្នេះថា៖ " ការដែលគ្រាន់តែបញ្ចូលឯកសារទៅក្នុងប្រព័ន្ធ

---

[7] សូមមើលស្ថិតិដែលបញ្ជាក់ឡើងវិញនូវចំនួនឯកសារ និងស្ថានភាពនៃការបកប្រែ នៅក្នុងសំណុំរឿង ០០២ (ជាឧបសម្ពន្ធ) សារអេឡិចត្រូនិករបស់ លោក Charles Muraya ថ្ងៃ សុក្រ ទី ១១ ខែ មីនា ឆ្នាំ ២០១១។

EDS (ស្មើនឹង Zylab នៅតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា) មិនមានន័យថាំបាច់ថា គឺជាការផ្តល់ដល់ជនជាប់ចោទ នូវលទ្ធភាពក្នុងការអាចចូលមើលឯកសារបានដោយងាយស្រួលនោះទេ" ប៉ុន្តែបែរជាមានន័យថា គឺជាការផ្តល់ដល់ភាគីការពារក្តីនូវកូនសោទូមួយដែលផ្ទុកនូវឯកសាររាប់ម៉ឺនជាសំណៅក្រដាស"[8] ទៅវិញ។

១៣. ដូច្នេះ លោក ខៀវ សំផន វាយតម្លៃថារាល់ឯកសារទាំងអស់នៅក្នុងសំណុំរឿង ០០២ មិន**"អាចរកបាន"** ដូចនៅក្នុងន័យនៃវិធាន ៨៧.៤ នៃវិធានផ្ទៃក្នុងនោះឡើយ។[9]

១៤. ម្យ៉ាងទៀត ស្របតាមទស្សនៈរបស់កម្ពុជាស្តីពីការស៊ើបអង្កេត ដែលចេញមកពីវប្បធម៌បារាំង និងស្ថិតនៅក្នុងធរមានបញ្ញត្តិរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា លោកយល់ឃើញថា **រាល់**ឯកសារទាំងអស់ដែលត្រូវបានបញ្ចូលទៅក្នុងសំណុំរឿង ០០២ ត្រូវតែអនុញ្ញាតឱ្យលោកចូលមើលបាន នៅអំឡុងពេលនៃការកាត់ក្តី ដូចនៅក្នុងករណីសំណុំរឿង ០០១ ផងដែរ។

១៥. នៅក្នុងន័យនេះ វិធាន ៩២ នៃវិធានផ្ទៃក្នុង ចែងអំពីលទ្ធភាពសម្រាប់ភាគីទាំងឡាយក្នុងការដាក់សារណាជាលាយលក្ខណ៍អក្សរ "រហូតដល់ការបិទកិច្ចពិភាក្សាដេញដោល" និងវិធាន ៨៧.៣ ចែងថា "ភ័ស្តុតាងដែលមាននៅក្នុងសំណុំរឿង ត្រូវបានចាត់ទុកថាបានលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ ឬ ភាគី បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ត្រូវបានអាន ឬ ត្រូវបានកំណត់បង្ហាញអត្តសញ្ញាណយ៉ាងសមស្របក្នុងសវនាការ។"

១៦. ទោះជានៅក្នុងករណីណាក៏ដោយ និងនៅពេលណាក៏ដោយ វិធានផ្ទៃក្នុងមិនដែលតម្រូវឱ្យលើកឡើងនូវភ័ស្តុតាង នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុង**លក្ខខណ្ឌមួយកំណត់**ថាភ័ស្តុតាងនោះមាននៅក្នុងបញ្ជីណាមួយនោះឡើយ។ ប្រសិនករណីនេះពិតជាកើតមានឡើងមែន នោះសញ្ញាណ

---

[8] តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់ប្រទេសរ៉ាន់ដា សហព្រះរាជអាជ្ញា ប្រឆាំងនឹង Karemera, Ngirumpatse និង Nzirorera សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ទាក់ទងនឹងតួនាទីនៃប្រព័ន្ធទំនាក់ទំនងអេឡិចត្រូនិក របស់ព្រះរាជអាជ្ញា នៅក្នុងការអនុវត្តកាតព្វកិច្ចទំនាក់ទំនង រឿងក្តីលេខ ICTR-98-44-AR73.7 កថាខណ្ឌ ១៣-១៥។

[9] វិធាន ៨៧.៤ នៃវិធានផ្ទៃក្នុងបានចែងថា ៖ "ក្នុងកំឡុងពេលសវនាការ តាមគំនិតផ្តួចផ្តើមរបស់អង្គជំនុំជម្រះ ឬ តាមការស្នើសុំរបស់ភាគី អង្គជំនុំជម្រះអាចកោះហៅ ឬស្តាប់ចម្លើយបុគ្គលណាម្នាក់ក្នុងឋានៈជាសាក្សី ឬទទួលយកនូវភ័ស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត។ [...] ភាគីដែលស្នើសុំត្រូវតែធ្វើឱ្យអង្គជំនុំជម្រះជឿជាក់ថាសក្ខីកម្ម ឬភ័ស្តុតាងដែលបានស្នើសុំនោះ **ពុំអាចរកបាន** នៅមុនពេលការចាប់ផ្តើមជំនុំជម្រះ។"

នៃសំណុំរឿងស៊ើបអង្កេតនឹងមិនមានន័យទៀតឡើយ ហើយវានឹងមានន័យយ៉ាងខ្លីថាត្រូវបដិសេធសំណុំឯកសាររាប់ពាន់ដែលប្រមូលបាន តាមរយៈការស៊ើបអង្កេតអស់ពេលជាច្រើនឆ្នាំ ក្នុងទិសដៅស្វែងរកការពិត។

## ស្តីពីយថាភាពនៃឯកសារមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា

១៧. ជាចុងក្រោយនេះ លោក ខៀវ សំផន មានបំណងជម្រាបជូនអង្គជំនុំជម្រះអំពីការមន្ទិលសង្ស័យជាខ្លាំងរបស់លោក ទាក់ទងនឹងយថាភាព និងឬសគល់នៃឯកសារ មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam)។

១៨. អង្គជំនុំជម្រះត្រូវរកឲ្យបាននូវឯកសារច្បាប់ដើម និងធានាយថាភាពនូវរាល់ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលអង្គជំនុំជម្រះមានបំណងពិនិត្យ ដែលក្នុងនោះរួមមានទាំងឯកសារមួយចំនួនរបស់មជ្ឈមណ្ឌលនេះ ដែលលោក ខៀវ សំផន បានភ្ជាប់ជាឧបសម្ព័ន្ធនាពេលបច្ចុប្បន្នផងដែរ។

១៩. ដោយផ្អែកលើការលើកឡើងពីខាងដើម បញ្ជីឯកសារដែលត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ នាពេលបច្ចុប្បន្ន គ្រាន់តែជាការបញ្ជាក់ដ៏សាមញ្ញមួយស្តីពីធាតុផ្សំសំខាន់ៗក្នុងចំណោមធាតុផ្សំផ្សេងៗទៀតដែលមាននៅក្នុងសំណុំរឿង ០០២ ដែល លោក ខៀវ សំផន មានបំណងលើកឡើងនៅចំពោះមុខអង្គជំនុំជម្រះ។

២០. ដូច្នេះ លោកសូមរក្សាសិទ្ធិលើកឡើង នៅពេលក្រោយៗទៀត រួមទាំងនៅក្រោយពេលការចាប់ផ្តើមជំនុំជម្រះ នូវរាល់ឯកសារទាំងឡាយដែលមាននៅក្នុងសំណុំរឿង ០០២ និងដែលលោកមិនអាចបានយល់ដឹង ដោយសារចំនួនឯកសារដ៏ច្រើនសម្បើមដែលគាត់មាន។

២១. លោក ខៀវ សំផន សូមដាក់ជាព័ត៌មាននូវបញ្ជីសៀវភៅ និងអត្ថបទមួយចំនួនដែលជាមូលដ្ឋាននៃការពិចារណារបស់គាត់ និងដែលជាគោលនៃការការពារក្តីរបស់គាត់ដែរ។ កំណត់សម្គាល់ទាំងនេះធ្វើឡើងដើម្បីធានាឲ្យបាននូវសុវត្ថិភាពគតិយុត្តិនៃកិច្ចដំណើរការនិតិវិធី និងដើម្បីសច្ចភាព សម្រាប់សហគមន៍អន្តរជាតិ និងប្រជាជនកម្ពុជា។

## អាស្រ័យហេតុនេះ

២២. សូមអង្គជំនុំជម្រះ មេត្តា ៖

- **ទទួលស្គាល់ថា** ការអនុវត្តវិធាន ៨០ នៃវិធានផ្ទៃក្នុង រំលោភលើគោលការណ៍សន្មតជាមុនថា គ្មានទោសរបស់លោក ខៀវ សំផន ដែលតាមរយៈគោលការណ៍នោះ បន្ទុកនៃភស្តុតាងគឺធ្លាក់លើសហព្រះរាជអាជ្ញា សិទ្ធិមានពេលវេលាគ្រប់គ្រាន់ និងភាពងាយស្រួលចាំបាច់សម្រាប់ត្រៀមការពារក្តី ប្រកបដោយសមភាពជាមួយនឹងសហព្រះរាជអាជ្ញា និងសិទ្ធិទទួលបានការជម្រះក្តី ដោយមិនមានភាពយឺតយ៉ាវហួសហេតុ
- **ទទួលយក** បញ្ជីឯកសារជាបណ្តោះអាសន្នរបស់លោក ខៀវ សំផន
- **អនុញ្ញាតឲ្យ**លោក ខៀវ សំផន អាចបង្ហាញឯកសារទាំងឡាយដែលមាននៅក្នុងសំណុំរឿងលេខ 00២ នៅពេលសវនាការ
- **ផ្តល់**នូវច្បាប់ដើមនៃឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ទាំងអស់ដែលអង្គជំនុំជម្រះចង់យកមកពិនិត្យនៅពេលសវនាការ និងធានាអំពីយថាភាពនៃឯកសារទាំងនោះ។

**រក្សាសិទ្ធិកែប្រែគ្រប់យ៉ាង**
**និងដើម្បីយុត្តិធម៌**

| | | | |
|---|---|---|---|
| P. | មេធាវី ស សូវាន<br>មេធាវី Jacques VERGÈS<br>មេធាវី Philippe GRECIANO | ភ្នំពេញ<br>ប៉ារីស<br>ប៉ារីស | [signatures] |
| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |